**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យ៉ង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.ព/លេខ ២៣/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត ព្រះវិហារ

*ភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨១នាក់ មកពីស្រុកនានានៅក្នុងខេត្តព្រះវិហារដែលក្នុងនោះមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៤៨%បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្តព្រះវិហារ កាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៩ ក្នុងខេត្តព្រះវិហារ ។

អភិបាលរងខេត្តព្រះវិហារ លោកស្រី **ខូយ ប៊ុនថាន** មានប្រសាសន៍ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធី នយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ១រួចមកហើយ ហើយក៏បានបន្តដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ បន្តទៀត ហើយសិក្ខាសាលានេះគឺដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋកំណត់នូវអ្វី ដែលជាអាទិភាពអ្វីដែលចាំបាច់មុនគេ នៅក្នុងមណ្ឌលរបស់ខ្លួន ។

សិក្ខាសាលានេះក៏មានការចូលរួមពីអាជ្ញាធរខេត្ត និងសមាជិកក្រុមប្រឹក្សាខេត្តនៅក្នុងមណ្ឌលព្រះវិហារ ឯកឧត្តម **នង ចន** មកពីគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **សុខ ណារឿន** មកពីគណបក្សសមរង្ស៊ី ។ ឯកឧត្តមសមាជិកក្រុមប្រឹក្សាខេត្តទាំងពីររូបបានទទួលយកលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងនេះ ហើយក៏បានសន្យាថា នឹងយកទៅរាយការណ៍ជូនក្រុមប្រឹក្សានៅពេលប្រជុំដើម្បីធ្វើសមាហរណកម្មដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តព្រះវិហារដូចខាងក្រោម:

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនាំឲជប់នៅក្នុងខេត្ត ព្រះវិហារ |
|---|
| ១) សុំអោយមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល តភ្ជាប់បណ្តាញអគ្គិសនីដល់ប្រជាពលរដ្ឋទូទាំងខេត្តព្រះវិហារ អោយបានប្រើប្រាស់គ្រប់គ្រាន់ និងមានតម្លៃត្រឹម ១000 រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ចាប់ពីឆ្នាំ២00៩ បញ្ចប់ក្នុងឆ្នាំ២០១៣។ សុំមន្ទីរឧស្សាហកម្មរ៉ែ និថាមពលជួយតបណ្តាញអគ្គិសនីពីស្ទឹងត្រែង មកព្រះវិហារឱ្យបានរួចរាល់ក្នុង ឆ្នាំ២០១០។ |
| ២) សុំមន្ទីរកសិកម្មជួយទប់ស្កាត់ ការប្រព្រឹត្តបទល្មើសនេសាទ ដូចជា ការប្រើថ្នាំបំពុល ម៉ាស៊ីនឆក់ ការដាក់ដៃ នៅគ្រប់រដូវ នៅតាមដងស្ទឹងសែន ឱ្យបាន ១០០% ចាប់ពីឆ្នាំ២00៩ នេះតទៅ។ |
| ៣) សុំជួសជុលផ្លូវចំនួន ៣ខ្សែ ដែលខ្សែទី១ ក្រាលកៅស៊ូ មានប្រវែង ៨0គម ទទឹង ១៥ម ចាប់ពីទីរួមខេត្ត ដល់ស្រុកឆែប ចាប់ពី ឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១២។ ខ្សែទី២ផ្លូវលំដែល មានក្រាលគ្រួសក្រហម ចាប់ពីកុងស៊ីចាស់ ទៅភូមិខ្យងហោង ក្រុងព្រះវិហារ ដែលមានប្រវែង ២គម ទទឹង ៧ម ចាប់ផ្តើមពីឆ្នាំ២០១០ អោយរួចនៅឆ្នាំ ២០១១។ ខ្សែទី៣ ផ្លូវលំក្រាលគ្រួសក្រហម ចាប់ពីភូមិគូលែនជើង ដល់ភូមិព្យួរជ្រូក ស្រុកគូលែន ប្រវែង ៣គ.ម ទទឹង ៧ម អោយរួចនៅឆ្នាំ ២០១១។ សុំស្ថាបនាលូតាមផ្លូវ ក្នុងក្រុងព្រះវិហារ សង្កាត់កំពង់ប្រណាក ដែលមានមុខកាត់ 0,៨ម អោយ បាន១០០% ចាប់កសាងពីដើមឆ្នាំ២០១០ និងបញ្ចប់ចុងឆ្នាំ២០១០។ |
| ៤) សុំឱ្យមន្ទីរពាណិជ្ជកម្ម ជួយរកទីផ្សារនាំចេញផលិតផលកសិកម្ម ដោយ ស្រូវ និងសណ្តែកសៀង ឱ្យមានតំលៃទាបបំផុតត្រឹម ១000រៀល ក្នុងមួយគីឡូក្រាមស្រូវ និងសណ្តែកទាបបំផុតត្រឹម ២៥00រៀល ក្នុងមួយគីឡូក្រាម នៅទូទាំងខេត្តព្រះវិហារ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៥) សុំឱ្យមន្ទីរបរិដ្ឋាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយថែរក្សាព្រៃឈើនៅតំបន់ជួរភ្នំត្បែង ក្នុងស្រុកសង្គមថ្មី ស្រុកគូលែន ស្រុក ត្បែងមានជ័យ និងស្រុករវៀង ដោយទប់ស្កាប់បទល្មើសកាប់បំផ្លាញព្រៃឈើ ឱ្យបាន១០០% នៅក្នុងខេត្តព្រះវិហារ ដោយអនុវត្តចាប់ ពីឆ្នាំ ២០0៩ តទៅ។ |
| ៦) សុំមន្ទីរសុរិយោដី និងផ្នែកពាក់ព័ន្ធផ្តល់ដីស្រែដល់គ្រួសារក្រីក្រ ដោយមួយគ្រួសារ ៥ហិចតា នៅក្នុងនៅភូមិគោកបេង សង្កាត់កំពង់ប្រណាក់ ប្រហែល ៥0គ្រួសារ និងនៅក្នុងភូមិឆែបខាងលិច ឃុំឆែបមួយ ស្រុកឆែប ៥0គ្រួសារ និងដីចំការ ចំនួន ៨0គ្រួសារ ទៀតនៅភូមិអូរក្លែងពណិ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ឱ្យបានក្នុង ឆ្នាំ ២០១១។ |
| ៧) សុំឱ្យសមត្ថកិច្ចជួយចាត់កំលាំងការពារសន្តិសុខ ដល់ជនរងគ្រោះដោយអំពើហឹង្សារក្នុងគ្រួសារ [គ្រួសារដែលធ្លាប់មានអំពើហឹង្សា ហើយរាយការណ៍ដល់ប៉ូលីស ] និងលុបបំបាត់ការជំរិតយកលុយពីប្រជាពលរដ្ឋ របស់ប៉ូលិសចរាចរដោយខុសច្បាប់ ឱ្យបាន ១០០% នៅទូទាំងខេត្តព្រះវិហារ ឱ្យបានចាប់ពីឆ្នាំ២០១០ តទៅ។ |
| ៨) សុំមន្ទីរអប់រំខេត្ត ជួយផ្តល់វគ្គបណ្តុះបណ្តាល កម្មវិធីសិក្សាថ្មី ក្នុងមួយឆ្នាំ ២វគ្គ ដល់គ្រូ ទាំង ៧ស្រុក ក្នុងខេត្តព្រះវិហារ ចាប់ពីឆ្នាំ ២០១០ តទៅ។ សុំមន្ទីរអប់រំ បង្កើតវិទ្យាល័យមួយកន្លែងនៅក្នុងស្រុកឆែប ១អគារ មាន ៥បន្ទប់ ទីចាត់ការមួយ បណ្ណាល័យមួយ ចាប់ផ្តើមពីឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១២។ សុំអាគារនៅសាលាបឋមសិក្សាហ្មសែត នៅសង្កាត់ប៉ាហាល |

| |
|---|
| ក្រុងព្រះវិហារ អោយបាននៅឆ្នាំ ២០១២។ សុំអាគារនៅអនុវិទ្យាល័យសង្គមថ្មី មួយខ្នង ៥បន្ទប់ ទីចាត់ការមួយ។ សុំបង្កើតសកលវិទ្យាល័យ មួយកន្លែងនៅក្នុងខេត្តព្រះវិហារ ដោយចាប់ផ្ដើមនៅឆ្នាំ ២០១០ បញ្ចប់នៅឆ្នាំ២០១១។ |
| ៩) សុំមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជួយរកការងារដល់ស្ត្រីងាយរងគ្រោះ (ដោយអំពើហឹង្សា, ជំងឺអេដស៍ ) អោយបាន ១០០% នៅខេត្តព្រះវិហារ ចាប់ពីឆ្នាំ ២០១០ នេះតទៅ។សុំតម្លើងប្រាក់ខែដល់គ្រូបង្រៀន និងមន្ត្រីរាជការ ឱ្យបាន ៥០% ជារៀងរាល់ឆ្នាំ នៃប្រាក់ខែបច្ចុប្បន្ន ចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាល ជួយរកទីផ្សារលក់ផលិតផល និងកំណត់តំលៃផលិតផល ដូចជា ដំឡូងមី សណ្ដែក ស្រូវ ពោត ល្ង ព្រមទាំង ឱ្យមានតំលៃខ្ពស់ជាងតម្លៃបច្ចុប្បន្ន ៣០% ចាប់ពីឆ្នាំ២០១០ តទៅ។ សុំឱ្យរាជរដ្ឋាភិបាលបង្កើតរោងចក្រផលិតម្សៅមី និងស្ករស នៅក្នុងក្រុងព្រះវិហារ ឱ្យបានក្នុងឆ្នាំ២០១០ និងបញ្ចប់ក្នុង ឆ្នាំ២០១១។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), គណៈកម្មាធិការអព្យាក្រឹតដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (NICFEC), អង្គការអភិវឌ្ឍន៍ទៅលើធនធានមនុស្ស និងព្រៃឈើ (KIPD), អង្គការពន្លកខ្មែរ ដែលក្នុងនោះមានការចូលរួម ពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកឆែប ស្រុករវៀង ស្រុកជាំក្សាន្ត ស្រុកជ័យសែន និងក្រុងព្រះវិហារនៅក្នុងខេត្តព្រះវិហារ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣)និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **គីម ឈន** អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិនុរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦